LONG BEACH
HEALTH & HUMAN SERVICES

# ពិធីការសំរាប់មជ្ឈមណ្ឌលទាយតន្និស/ភូនច្ចាល់ និងតារាងច្ចាល់ច្បោះ:

## ឧបសម្ព័ន្ធ E

**ការធ្វើបច្ចុប្បន្នភាពថ្មីៗ:**

- 3/31/21 - គឺតត្រឹមថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០២១, ខោនធីឡូសអានជឺឡេស, រួមទាំងក្រុងឡុងប៊ិចផងដែរ គឺដាក់អោយស្ថិតនៅចំណាត់ថ្នាក់ពណ៌លឿង ក្រោមផែនការមេរបស់រដ្ឋ ចំពោះសេដ្ឋកិច្ចដែលមានសុវត្ថិភាពជាងមុន។ ជាលទ្ធផលនៃការផ្លាស់ប្តូរចំណាត់ថ្នាក់នេះ គ្មានការផ្លាស់ប្តូរអ្វីនោះឡើយ។
- 3/10/21
  - អាចនឹងរៀបចំអោយមានការលេងជាក្រុម ឬការលេងដែលបានបង្កើតឡើង មិនអោយលើសពី ៤ នាក់ ក្នុងមួយប្រកួត ប្រសិនបើការលេងបែបនេះនឹងមិនបង្កើនវត្តមាននៃចំនួនមនុស្ស នៅកន្លែងលេងនោះ ក្នុងពេលតែមួយ។ ត្រូវរៀបចំកាលវិភាគទុកជាមុនចំពោះការលេងជាក្រុម ឬការលេងដែលបានបង្កើតឡើង ដើម្បីឱ្យទុកអោយមានចន្លោះពេលឃ្លាតគ្នា ពីហ្គេមនីមួយៗមិនតិចជាង ១០ នាទី។ ត្រូវលើកទឹកចិត្តអោយបង់ប្រាក់ជាមុន និងការចុះឈ្មោះតាមអេឡិចត្រូនិក សម្រាប់ការលេងជាក្រុម ឬការលេងដែលបានបង្កើតឡើង។ មានការលើកទឹកចិត្តជាខ្លាំង អោយប្រើនូវប័ណ្ណពិន្ទុអេឡិចត្រូនិក, ព័ត៌មាន និងសន្លឹកច្បាប់។ បើកន្លែងណាដែលប្រើប័ណ្ណពិន្ទុក្រដាសវិញនោះ,សមាជិកម្នាក់ក្នុងក្រុម គួរតែរក្សាពិន្ទុអោយកីឡាករទាំងអស់ ដើម្បីជៀសវាងការប៉ះពាល់ដែលមិនចាំបាច់ រវាងកីឡាករទាំងឡាយ។ ការដាក់បង្ហាញអ្នកលក់នៅនឹងកន្លែង ត្រូវតែគោរពតាមពិធីសារលក់រាយដោយផ្ទាល់ និងត្រូវមានចម្ងាយយ៉ាងតិច ៦ ហ្វីត រវាងការដាក់បង្ហាញនានារបស់អ្នកលក់។
  - ត្រូវហាមឃាត់នូវការប្រកួត ឬព្រឹត្តិការណ៍ដែលមានការចូលរួមច្រើនជាងពីរក្រុម។ អនុញ្ញាតិយ៉ាងច្រើនបំផុត អោយមានការប្រកួតតែម្តងប៉ុណ្ណោះ, ក្នុងមួយក្រុម, ក្នុងមួយថ្ងៃ លើកលែងតែមានការអនុញ្ញាតនៅទីនេះ។ "ក្រុម" ត្រូវបានកំណត់ជាក្រុមកីឡាករដែលបង្កើតជាក្រុមមួយ នៅផ្នែកម្ខាងទៀត នៅក្នុងការប្រកួតកីឡា។ "ក្រុម" មិនរាប់បញ្ចូលនូវក្រុម ឬកំរិតច្រើន ដែលមកពីលីក ឬក្រុមដែលមានបទពិសោធន៍ខ្លាំង ដូចគ្នាតែមួយ (ឧទាហរណ៍ ក្រុមថ្មីថ្មោង, ក្រុមមិនសូវមានបទពិសោធន៍ប្រកួត និងក្រុមមានបទពិសោធន៍ខ្ពស់នានា និងពីសាលា ឬលីកតែមួយ ត្រូវបានគេចាត់ទុកថា ជាក្រុមផ្សេងគ្នា)។
  - ក្នុងមួយថ្ងៃ ដែលអាចត្រូវលេងច្រើនបំផុត គឺប្រកួតបានតែម្តងប៉ុណ្ណោះ, ក្នុងមួយក្រុម និង/ឬចំពោះបុគ្គលម្នាក់ (ឧទាហរណ៍ គ្មានការប្រកួតវិលជុំ ឬការប្រកួតច្រើនក្នុងថ្ងៃតែមួយជាដាច់ខាត)។
- ការផ្លាស់ប្តូរនានា បានរំលេចអោយឃើញជាពណ៌លឿង។

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

ពិធីការនេះ នឹងត្រូវបានបំពេញដោយមជ្ឈមណ្ឌលវាយ តិន្នីស/កូនបាល់ និងតារាងបាល់បោះ។ តម្រូវការនានាខាងក្រោម អនុវត្តចំពោះមជ្ឈមណ្ឌលតិន្នីស/កូនបាល់ និងតារាងបាល់បោះទាំងអស់។ បន្ថែមពីលើលក្ខ័ណ្ឌ ដែលបានដាក់លើមជ្ឈមណ្ឌលតិន្នីសទាំងអស់ ដោយមន្ត្រីសុខាភិបាល សំរាប់ប្រតិបត្តិការកំសាន្តសប្បាយនៅខាងក្រៅ, ដែលមាន ឬមើលឃើញនៅលើគេហទំព័រ https://covid19.ca.gov/industry-guidance/,, មជ្ឈមណ្ឌលតិន្នីស ក៏ត្រូវគោរពតាមលក្ខ័ណ្ឌដែលបានដាក់ចេញនៅក្នុងពិធីការ នេះផងដែរ។ ពិធីការនេះ ត្រូវតែបានអនុវត្ត និងបានបិទប្រកាស ឬផ្សាយមុនពេលដំណើរការ ។

សូមកត់សំគាល់៖ ឯកសារនេះអាចត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលព័ត៌មាន និងធនធាននានាបន្ថែមទៀត អាចរកបាន ដូច្នេះត្រូវប្រាកដថានឹងពិនិត្យមើលលើគេហទំព័រ ឡុងប៊ិច COVID-19 នៅឯ www.longbeach.gov/covid19 ជាប្រចាំដើម្បីទទួលបានព័ត៌មានថ្មីៗនេះ ចំពោះឯកសារនេះ។

ប្រតិបត្តិការលក់រាយ ត្រូវតែគោរពតាមពិធីសារនៃការលក់រាយដោយមនុស្សផ្ទាល់ (ឧបសម្ព័ន្ធ B) ។

ភោជនីយដ្ឋាន, សេវាកម្មម្ហូបអាហារ, និងសម្បទានម្ហូបអាហារ ត្រូវតែគោរពតាមពិធីសារភោជនីយដ្ឋាន (ឧបសម្ព័ន្ធ H) ។

កីឡាសម្រាប់មនុស្សពេញវ័យ និងយុវវ័យ ត្រូវតែគោរពតាមពិធីសារកីឡាសំរាប់យុវជន និងមនុស្សពេញវ័យ របស់រដ្ឋ ដែលមាននៅលើគេហទំព័រ https://www.cdph.ca.gov/Programs/CID/DCDC/Pages/COVID-19/small-groups-child-youth.aspx

បញ្ជីផ្ទៀងផ្ទាត់នេះ រួមមាននូវ៖

(1) គោលនយោបាយនានា និងការអនុវត្តនៅកន្លែងធ្វើការ ដើម្បីការពារសុខភាពនិយោជិក

(2) វិធានការណ៍នានា ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា

(3) វិធានការណ៍នានា ដើម្បីធានាការគ្រប់គ្រងការឆ្លង

(4) ការប្រាស្រ័យទាក់ទងជាមួយនិយោជិក និងសាធារណៈជន

(5) វិធានការណ៍នានា ដើម្បីធានាបាននូវការទទួលបាននូវសេវាកម្មចាំបាច់ ប្រកបដោយសមធម៌

**មជ្ឈមណ្ឌលវាយតិន្នីស ឬកូនបាល់ទាំងអស់ ត្រូវអនុវត្តនូវរាល់វិធានការណ៍នានាដែលអាចអនុវត្តបាន ដែលមានរាយ ខាងក្រោម ហើយត្រៀមក្នុងការពន្យល់អំពីមូលហេតុអ្វី បានជាវិធានការណ៍ណាមួយ ដែលមិនត្រូវបានអនុវត្តនោះ មិនអាចអនុវត្តបាន។**

**ឈ្មោះមជ្ឈមណ្ឌលវាយតិន្នីស ឬកូនបាល់ :** ______________________________

**អាសយដ្ឋានកន្លែង:** ______________________________

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

## A. ការកត់ឈ្មោះចូលនូវអ្នកលេង, ការលេងតិន្នីស និងអ្វីៗនៅជុំវិញក្លឹបហៅស៍ - ការដាក់កំរឹត

- ☐ ក្លឹបហៅស៍ នៅតែត្រូវបិទទ្វារ ចំពោះសាធារណៈជន។
- ☐ ផ្លាកសញ្ញាណែនាំ និងព័ត៌មាន ត្រូវបានបិទផ្សាយនៅគ្រប់ទីកន្លែងទាំងអស់ ទាក់ទងទៅនឹងការគ្រប់គ្រងការឆ្លង, ឃ្លាតឆ្ងាយរាងកាយពីគ្នា និងការប្រើប្រាស់គំរបមុខ។
- ☐ ជូនដំណឹងដល់អតិថិជន និងសមាជិក អំពីពិធីការសុវត្ថិភាពទាំងអស់ ជាមុន។
- ☐ អតិថិជនតម្រូវអោយពាក់គម្របមុខគ្រប់ពេលវេលាទាំងអស់ ក្នុងកំឡុងពេលដែលនៅទីកន្លែងនោះ។ ការបិទគម្របមុខក្រណាត់ មិនគួរត្រូវពាក់អោយកុមារក្មេងៗ ដែលមានអាយុក្រោម ២ ឆ្នាំ, អ្នកណាម្នាក់ ដែលមានស្ថានភាពសុខភាព, ស្ថានភាពសុខភាពផ្លូវចិត្ត, ឬពិការភាពដែលរារាំងពួកគេ មិនអាចអោយពាក់គម្របមុខបាន, ឬបើមិនដូច្នេះទេ ពួកគេមិនអាចដោះចេញនូវម៉ាស់ ឬគម្របមុខបានឡើយ ប្រសិនបើគ្មានជំនួយទេនោះ។
- ☐ ភ្ញៀវ ឬតំណាងផ្នែកលក់ទាំងឡាយ មិនត្រូវបានអនុញ្ញាតិអោយស្ថិតនៅក្នុងក្លឹបហៅស៍ និងតំបន់ហាងលក់ទំនិញឡើយ។ នេះរួមបញ្ចូលទាំងអ្នកចែកចាយខាងក្រៅ និងអ្នកតំណាងក្រុមហ៊ុនផលិត។ ការប្រជុំ ត្រូវបានធ្វើឡើងតាមទូរស័ព្ទ ឬវេទិកានិម្មិតនានា។
- ☐ ការបង់ថ្លៃឈ្នួល ត្រូវបានធ្វើឡើងពី ឬតាមបង្អួចដែលបែរមុខទៅរកកន្លែងចាប់ផ្តើម នៅខាងក្រៅដែលមានរួចស្រាប់ ឬពីតុកត់ឈ្មោះចូលនៅខាងក្នុងកន្លែង។ សញ្ញាសំគាល់ចម្ងាយ ៦ ហ្វីត នៃការឃ្លាតឆ្ងាយរាងកាយពីគ្នា ត្រូវបានតំឡើងដើម្បីអោយអតិថិជនទាំងឡាយដឹងអំពីកន្លែងដែលត្រូវរង់ចាំបង់ប្រាក់។
- ☐ ទាមទារអោយមានការកក់ ហើយអ្នកលេង ឬកីឡាករត្រូវបានលើកទឹកចិត្តអោយបង់ប្រាក់ជាមុន ដោយប្រើកាតដេបីត/ក្រេឌីត នៅពេលកក់។
- ☐ លើកទឹកចិត្តអោយមានការទូទាត់ជាអំណោយ, កាតដេបីត ឬកាតក្រេឌីត។
- ☐ ការគូសសញ្ញាចំណាំ ឬការកំណត់ព្រំដែននានា ត្រូវបានបង្កើតឡើង ដើម្បីបង្កើតជារបាំងដែលមានចម្ងាយ ៦ ហ្វីត ដើម្បីកាត់បន្ថយនូវទំនាក់ទំនងជិតស្និទ្ធ រវាងនិយោជក និងសាធារណៈជន។
- ☐ ទឹកលាងដៃសម្លាប់មេរោគ, សាប៊ូ និងទឹក ឬ ថ្នាំ ឬវត្ថុ/ជូតសំឡាប់មេរោគ ដែលមានប្រសិទ្ធិភាព ត្រូវដាក់អោយមានសំរាប់អោយប្រើ ចំពោះអ្នកលេងនៅឯ ឬនៅក្បែរច្រកចូលនីមួយៗ ឆ្ពោះទៅកាន់កន្លែងលេង នៅតាមរទេះភេសជ្ជៈ និងស្ថានីយ៍/កន្លែងអាហារនានា និងបន្ទប់ទឹកទាំងឡាយ, និងចំណុចសំខាន់ៗផ្សេងទៀត។
- ☐ ការកក់ទុក គឺមិនតិចជាង ១០ នាទី ពីគ្នាឡើយ។ អ្នកលេង ត្រូវបានលើកទឹកចិត្ត អោយចូលមកកាន់កន្លែងនេះមិនលើសពី ១០ នាទី មុនពេលពេលវេលាដែលរំពឹងថា នឹងបានលេង។
- ☐ កីឡានេះ គឺត្រូវបានកំណត់ចំពោះអ្នកលេង មិនអោយលើសពី ៤ នាក់ ដែលអ្នកទាំងអស់នោះ មិនចាំបាច់មកពីគ្រួសារតែមួយ ឬរស់នៅក្នុងយូនីតតែមួយនោះឡើយ។ ក្រុមនីមួយៗ ត្រូវតែមានស្ថេរភាព (ឧទាហរណ៍., មនុស្សនោះមិនអាច

ជំនួស អោយចូល ឬចេញពីក្រុមបាននោះទេ)។

- របស់របរនីមួយៗនៃឧបករណ៍ដែលបានជួល ត្រូវតែសំអាត ឬជូតជំរះ ទាំងស្រុងជាមួយនឹងថ្នាំសម្លាប់មេរោគដែលមានប្រសិទ្ធិភាពប្រឆាំងជំងឺ COVID-19 បន្ទាប់ពីការប្រើប្រាស់រួចម្តងៗ។
- និយោជិកបានត្រូវចាត់ចែងអោយ ធ្វើអនាម័យឧបករណ៍ជួល នៅចន្លោះពេលប្រើប្រាស់។
- ខោនធើសាធារណៈ និងបង្គួចសេវាកម្មនានា ត្រូវបានធ្វើអនាម័យអោយបានញឹកញាប់ ជាមួយនឹងថ្នាំសំឡាប់មេរោគដែលមានប្រសិទ្ធិភាព ប្រឆាំងនឹងមេរោគ COVID-19។
- រាល់ច្រកទ្វារចូល និងរនាំងដៃកាន់តាមជណ្តើរ ត្រូវបានស្រោបរុំដោយបង់ស្ទីតយ៉ាងប្រយ័ត្នប្រយែង ដើម្បីកុំ អោយប៉ះពាល់ ឬបើមិនដូច្នោះទេ ត្រូវជូតសំអាត រៀងរាល់ម៉ោង។
- ច្រកទ្វារទាំងអស់ត្រូវបានដោះចេញ ឬទុកអោយចំហរ ដើម្បីការពារការប៉ះពាល់ ប្រសិនបើអាចធ្វើទៅបាន។ ប្រសិនបើកន្លែងនេះ មានច្រកចូលច្រកចូលតាមចំហៀងរជំទូលាយឆ្លោះទៅកាន់ទីលាន, ការប្រើប្រាស់វា ត្រូវបានណែនាំ។
- ទីលានជំនួស ត្រូវបានបម្រុងទុកសម្រាប់ការលេង ប្រសិនបើមិនមានរនាំងបាំង ដូចជារបង រវាងទីលាន។
- ក្តារដាក់ពិន្ទុទាំងអស់ ត្រូវបានយកចេញពីទីលាន ដើម្បីការពារនូវការប៉ះពាល់។
- ធុងសំរាម គឺគ្មានការប៉ះពាល់។ ដកគំរបចេញ ប្រសិនបើមាន។
- រាល់បន្ទប់ទឹកទាំងអស់ ត្រូវថែទាំលាងសំអាត និងសំឡាប់មេរោគអោយបានញឹកញាប់។ ទ្វារត្រូវបានបើកចំហរ នៅពេលដែលអាចធ្វើបាន ដើម្បីកាត់បន្ថយនូវការប៉ះពាល់ដៃ ឬផ្ទៃទ្វារ។
- ការលក់របស់ក្នុងហាង ត្រូវតែអនុវត្តតាម ឬប្រកាន់ខ្ជាប់តាមពិធីការ លក់រាយ។ ទ្វារទាំងអស់នៅកន្លែង ឬតាមទីតាំង ត្រូវបានបើកចំហរ នៅពេលណាដែលអាចធ្វើទៅបាន។
- អ្នកលេង តម្រូវអោយចាកចេញពីទ្រព្យសម្បត្តិភ្លាមៗ នៅពេលបញ្ចប់ការលេង។ មិនអនុញ្ញាតអោយមានការជួបជុំគ្នា ឬបើកបរតកន្ទុយជឹតៗគ្នា នៅក្នុងកន្លែងចតរថយន្តឡើយ។
- អ្នកលេងត្រូវបានតម្រូវអោយនៅផ្នែកម្ខាងនៃទីលានរបស់ពួកគេ និងជៀសវាងការផ្លាស់ប្តូរចុងទីលាន។
- ការត្រួតពិនិត្យរោគសញ្ញា ត្រូវបានធ្វើឡើងមុនពេលភ្ញៀវ ចូលក្នុងគ្រឹះស្ថានឬទីកន្លែង។ ការត្រួតពិនិត្យត្រូវ តែរាប់បញ្ចូលទាំងការក្អក, ដង្ហើមខ្លី/ដង្ហក់, ពិបាកដកដង្ហើម, គ្រុនក្តៅ ឬញាក់ និងថាតើបច្ចុប្បន្ននេះ បុគ្គលនោះកំពុង ស្ថិតនៅក្រោច្បាប់ដាក់អោយនៅឯកោ ឬធ្វើចត្តាឡីស័ក្ក/ការដាក់ខ្លួនអោយនៅដាច់ដោយឡែកពីគេ។ ត្រូវធ្វើការត្រួតពិនិត្យទាំងនេះដោយមនុស្សផ្ទាល់ ឬតាមរយៈវិធីសាស្រ្តជំនួសផ្សេងៗ ដូចជាការត្រួតពិនិត្យតាមអ៊ីនធឺរណិង ឬតាមរយៈការបិទឬដាក់ផ្លាកសញ្ញា នៅតាមច្រកចូល ដោយបញ្ជាក់ថាភ្ញៀវដែលមានរោគសញ្ញាទាំងនេះ មិនគួរចូលក្នុងបរិវេណនោះឡើយ។
- និយោជិកទាំងអស់ ត្រូវបានរំលឹកអោយប្រកាន់ខ្ជាប់នូវសកម្មភាពការពារផ្ទាល់ខ្លួននានា ជារួមមាន៖

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

    - ស្នាក់នៅផ្ទះ នៅពេលដែលអ្នកឈឺ។ ស្នាក់នៅផ្ទះយ៉ាងហោចណាស់ ៣ ថ្ងៃ (៧២ ម៉ោង) បន្ទាប់ពីការជាសះស្បើយ, ដែលមានន័យថា គ្រុនក្តៅរបស់អ្នកបានត្រូវដោះស្រាយ ដោយមិនចាំបាច់ប្រើថ្នាំបន្ថយកំដៅទេ ហើយវាមានភាពប្រសើរឡើង នៃរោគសញ្ញាផ្លូវដង្ហើមនានារបស់អ្នក (ឧទាហរណ៍., ក្អក, ដង្ហើមខ្លី ឬដង្ហក់), និងយ៉ាងហោចណាស់ ១០ ថ្ងៃបានកន្លងផុតទៅ តាំងតែពីរោគសញ្ញាដំបូងរបស់អ្នក បានបង្ហាញចេញមក។
    - លាងដៃរបស់អ្នកអោយបានញឹកញាប់ ជាមួយសាប៊ូ និងទឹក យ៉ាងហោចណាស់ ២០ វិនាទី។ ប្រសិនបើមិនមានសាប៊ូ និងទឹកទេនោះ, សូមប្រើទឹកលាងដៃអនាម័យដែលមានជាតិអាល់កុល យ៉ាងហោចណាស់ ៦០%។ លាងដៃរបស់អ្នក មុនពេលញ៉ាំអាហារ, បន្ទាប់ពីប្រើបន្ទប់ទឹករួច និងក្រោយពេលក្អក និងកណ្តាស់។
    - ខ្ទប់ក្អក និងកណ្តាស់របស់អ្នក ជាមួយនឹងក្រដាសស្តើង ហើយបន្ទាប់មក បោះក្រដាសស្តើងនោះចោល ហើយសម្អាតដៃរបស់អ្នកភ្លាមៗ។ ប្រសិនបើអ្នកមិនមានក្រដាសស្តើងទេនោះ សូមប្រើកែងដៃរបស់អ្នក (មិនមែនដៃរបស់អ្នកទេ)។
    - កុំប៉ះពាល់មាត់, ភ្នែក, ច្រមុះរបស់អ្នក ដោយដៃដែលមិនទាន់លាងសំអាត។
    - ជៀសវាងការទំនាក់ទំនង ឬប៉ះពាល់ជាមួយមនុស្សឈឺ។
    - ជៀសវាងការចែករំលែករបស់របរប្រើប្រាស់ ដូចជាទូរស័ព្ទ ឬឧបករណ៍ផ្សេងៗទៀត។ ប្រសិនបើឧបករណ៍ត្រូវតែចែករំលែក ត្រូវធ្វើអោយប្រាកដថា ជូតសំអាតវា ដោយប្រើប្រដាប់ជូតសំឡាប់មេរោគ មុន និងក្រោយ ពេលចែករំលែក។
    - សង្កេតជានិច្ច នូវចម្ងាយការងាររបស់អ្នក នៃទំនាក់ទំនងជាមួយនឹងបុគ្គលិកផ្សេងទៀត។ ត្រូវរក្សាការ នៅដាច់ឆ្ងាយពីគ្នាដែលបានណែនាំ យ៉ាងតិចបំផុត ៦ ហ្វីត ពីអ្នកដទៃ លើកលែងតែការងារជាក់លាក់ ដែលតម្រូវអោយមានចំងាយតិចជាង ហើយត្រូវពាក់គម្របមុខ នៅពេលធ្វើការជិត ឬជាមួយអ្នកដទៃ។
    - សំឡាប់មេរោគចំពោះ ឬទៅលើវត្ថុ និងផ្ទៃដែលបានប៉ះពាល់ជាញឹកញាប់ ដូចជាស្ថានីយការងារ, ក្តារចុច, ទូរស័ព្ទ, ដៃរទេះរុញ, ម៉ាស៊ីនផ្សេងៗ, ឧបករណ៍ចែករំលែកទាំងឡាយ និងប្រដាប់មូលកាន់តាមមាត់ទ្វារ។ នេះគួរតែត្រូវបានធ្វើរៀងរាល់ម៉ោង ក្នុងកំឡុងពេលម៉ោងធ្វើការ។
    - លើកទឹកចិត្តបុគ្គលិក អោយជំនួសការចាប់ដៃជាមួយនឹងទម្រង់ស្វាគមន៍នានា ដោយមានការប៉ះពាល់តិចបំផុត ចំពោះអតិថិជន និងសមាជិកទាំងឡាយ។
- លុបបំបាត់ការវាយនាឡិការចេញចូលនូវម៉ោងធ្វើការ ឬចាត់តាំងអ្នកគ្រប់គ្រង/បុគ្គលម្នាក់ នូវទំនួលខុសត្រូវក្នុងការកំណត់ត្រាម៉ោងចូល/ចេញ របស់និយោជិកទាំងអស់។
- ច្បាប់ចតចំលងនៃពិធីការនេះ ត្រូវបានចែកចាយដល់និយោជិកទាំងអស់។

**ដើម្បីរាយការណ៍ការចំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

## B. ការបង្វឹក

- ☐ មេរៀនឯកជនត្រូវបានអនុញ្ញាតិអោយ ដោយប្រើនូវបច្ចេកទេសដើម្បីអនុញ្ញាតិអោយមានចំងាយ ៦ ហ្វីត ឬច្រើនជាងសំរាប់បុគ្គលម្នាក់ៗ។ ការបង្រៀន ឬការបង្វឹកជាក្រុម អនុញ្ញាតិជាមួយនឹងក្រុម ដែលកំណត់ មិនអោយលើសពីគ្រូបង្វឹក/អ្នកណែនាំចំនួន ២ នាក់ បង្ហាត់ទៅកាន់សិស្ស ចំនួន ១៤ អ្នក។
- ☐ អ្នកជំនាញបង្រៀនទាំងឡាយ នឹងត្រូវបានចាត់តាំងនូវទីលានជាក់លាក់ និងថ្ងៃ និងម៉ោងជាក់លាក់ ដែលអាចធ្វើទៅបាន។
- ☐ មានតែកន្ត្រក, ម៉ាស៊ីនចែកចាយបាល់ និងម៉ាស៊ីនប្រមូលបាល់ ត្រូវបានអនុញ្ញាតិនៅលើទីលាន។
- ☐ អ្នកលេង ត្រូវបានលើកទឹកចិត្តអោយប្រើនូវរ៉ាកែត ឬប្រដាប់វាយ/ជើងរបស់ពួកគេ ដើម្បីរុញបាល់ត្រឡប់មកវិញ និង/ឬវាយគ្រាប់បាល់នោះ ទៅអោយគ្រូរបស់ពួកគេវិញ ដើម្បីកុំជៀសវាននូវការប្រើដៃ និងការប៉ះពាល់គ្រាប់បាល់។
- ☐ អ្នកលេង នឹងមិនត្រូវគ្រប់គ្រងឧបករណ៍ហ្វឹកហាត់ណាមួយឡើយ។
- ☐ បាល់ ត្រូវបានដាក់កម្រិតចំពោះសិស្សម្នាក់ៗ។ បាល់អាចត្រូវបានផ្តល់អោយដោយអ្នកគាំទ្រ/អ្នកជំនាញ ឬសិស្ស។ ការប្រើប្រាស់សំណុំបាល់ដូចគ្នា ត្រូវបានហាមឃាត់ រវាងសិស្សច្រើននាក់។
- ☐ អ្នកជំនាញ នឹងប្រើស្រោមដៃនៅលើដៃ ដែលមិនមែនជារបស់ពួកគេ។

## C. កូនបាល់ ឬគ្រាប់បាល់តិន្នីស

- ☐ អ្នកលេងត្រូវតែយកកូនបាល់ផ្ទាល់ខ្លួនរបស់ពួកគេមកជាមួយ ដែលគួរតែត្រូវបានដាក់សញ្ញាសម្គាល់ដើម្បីចង្អុលបង្ហាញ ថាតើកូនបាល់មួយណាដែលពួកគេបានយកមក។ អ្នកលេង ត្រូវតែយកកូនបាល់របស់ពួកគេត្រឡប់ទៅវិញជាមួយ នៅពេលពួកគេចាកចេញ។

## D. សំភារៈតិន្នីស

- ☐ ការចែករំលែកឧបករណ៍តិន្នីស ត្រូវបានហាមឃាត់។
- ☐ ម៉ាស៊ីនចែកចាយបាល់, កន្ត្រកបាល់ និងម៉ាស៊ីនប្រមូលបាល់ ត្រូវបានធ្វើអនាម័យរវាងការប្រើប្រាស់ម្តងៗ។ ការប្រើប្រាស់បំពង់បាល់ និងកន្ត្រក ដើម្បីប្រមូលយកបាល់ដែលនៅរាយប៉ាយ បន្ទាប់ពីម៉ាស៊ីនបាល់ដែលបានប្រើ ដើម្បីកំរឹតនូវទំនាក់ទំនង ត្រូវបានលើកទឹកចិត្ត។
- ☐ ជៀសវាងការប្រើប្រាស់ឧបករណ៍ដែលមិនចាំបាច់ ដូចជាខ្សែរបោះទំលាក់។

## E. ការប្រកួត និងការលេងជាក្រុម

- ត្រូវកំណត់ហ្គេមនានាទុកជាមុន មិនអោយមានអ្នកលេង លើសពី ៤ នាក់ ដែលមិនចាំបាច់មកពីគ្រួសារតែមួយ ឬយូនីត រស់នៅតែមួយនោះឡើយ)។ ក្រុមនីមួយៗត្រូវតែមានស្ថេរភាព (ឧទាហរណ៍ មនុស្សនោះមិនអាចជំនួស ឬចេញពីក្រុមបាន ទេ)។
- អាចនឹងរៀបចំអោយមានការលេងជាក្រុម ឬការលេងដែលបានបង្កើតឡើង មិនអោយលើសពី ៤ នាក់ ក្នុងមួយប្រកួត ប្រសិនបើការលេងបែបនេះនឹងមិនបង្កើនវត្តមាននៃចំនួនមនុស្ស នៅកន្លែងលេងនោះ ក្នុងពេលតែមួយ។ ត្រូវរៀបចំកាលវិភាគទុកជាមុនចំពោះការលេងជាក្រុម ឬការលេងដែលបានបង្កើតឡើង ដើម្បីឱ្យទុកអោយមានចន្លោះពេលឃ្លាតគ្នា ពីហ្គេមនីមួយៗមិនតិចជាង ១០ នាទី។ ត្រូវលើកទឹកចិត្តអោយបង់ប្រាក់ជាមុន និងការចុះឈ្មោះតាមអេឡិចត្រូនិក សម្រាប់ការលេងជាក្រុម ឬការលេងដែលបានបង្កើតឡើង។ មានការលើកទឹកចិត្តជាខ្លាំង អោយប្រើនូវប័ណ្ណពិន្ទុអេឡិចត្រូនិក, ព័ត៌មាន និងសន្លឹកច្បាប់។ បើកន្លែងណា ដែលប្រើប័ណ្ណពិន្ទុក្រដាសវិញនោះ,សមាជិកម្នាក់ក្នុងក្រុម គួរតែរក្សាពិន្ទុអោយកីឡាករទាំងអស់ ដើម្បីជៀសវាងការប៉ះពាល់ដែលមិនចាំបាច់ រវាងកីឡាករទាំងឡាយ។ ការដាក់បង្ហាញអ្នកលក់នៅនឹងកន្លែង ត្រូវតែគោរពតាមពិធីសារលក់រាយដោយផ្ទាល់ និងត្រូវមានចម្ងាយយ៉ាងតិច ៦ ហ្វីត រវាងការដាក់បង្ហាញនានារបស់អ្នកលក់។
- ត្រូវហាមឃាត់នូវការប្រកួត ឬព្រឹត្តិការណ៍ដែលមានការចូលរួមច្រើនជាងពីរក្រុម។ "ក្រុម" ត្រូវបានកំណត់ជាក្រុមកីឡាករដែលបង្កើតជាក្រុមមួយ នៅផ្នែកម្ខាងទៀត នៅក្នុងការប្រកួតកីឡា។ "ក្រុម" មិនរាប់បញ្ចូលនូវក្រុម ឬកំរឹតច្រើន ដែលមកពីលីក ឬក្រុមដែលមានបទពិសោធន៍រួមតែមួយ (ឧទាហរណ៍ ក្រុមថ្មីថ្មោង, ក្រុមមិនសូវមានបទពិសោធន៍ប្រកួត និងក្រុមមានបទពិសោធន៍ខ្ពស់នានា និងពីសាលា ឬលីកតែមួយ ត្រូវបានគេចាត់ទុកថា ជាក្រុមផ្សេងគ្នា)។
- ក្នុងមួយថ្ងៃ ដែលអាចត្រូវលេងបានច្រើនបំផុត គឺប្រកួតបានតែម្តងប៉ុណ្ណោះ, ក្នុងមួយក្រុម (ឬចំពោះបុគ្គលម្នាក់ ប្រកួតបានតែមួយហ្គេមតែប៉ុណ្ណោះ) (ឧទាហរណ៍ គ្មានការប្រកួតវិលជុំ ឬការប្រកួតច្រើនក្នុងថ្ងៃតែមួយជាដាច់ខាត)។

## F. ពិធីការនិយោជិក

- ត្រូវបង្គាប់អោយធ្វើដូច្នោះ ចំពោះមនុស្សគ្រប់រូបដែលអាចបំពេញភារកិច្ចការងាររបស់ពួកគេពីផ្ទះ ។
- បុគ្គលិកងាយរងគ្រោះ (អ្នកដែលមានអាយុលើសពី ៦៥ ឆ្នាំអ្នកដែលមានបញ្ហាសុខភាពរ៉ាំរ៉ៃ) ត្រូវបានចាត់តាំងឱ្យធ្វើការដែលអាចធ្វើបានពីផ្ទះនៅពេលណាដែលអាចធ្វើទៅបាន។
- និយោជិកទាំងអស់ ត្រូវបានគេប្រាប់មិនអោយមកធ្វើការ ប្រសិនបើឈឺ។ គោលនយោបាយឈប់សម្រាកនៅកន្លែងធ្វើការ ត្រូវបានពិនិត្យឡើងវិញ និងបានត្រូវកែប្រែ ដើម្បីធានាថានិយោជិកមិនត្រូវបានពិន័យ នៅពេលពួកគេស្នាក់នៅផ្ទះដោយសារជំងឺ។
- និយោជិកត្រូវបានផ្តល់ព័ត៌មានអំពីអត្ថប្រយោជន៍ នៃការឈប់សម្រាកដែលបានឧបត្ថម្ភដោយនិយោជក ឬរដ្ឋាភិ បាល ដែលនយោជិក អាចមានសិទ្ធិទទួលបាន ដែលនឹងធ្វើឱ្យវាកាន់តែមានភាពងាយស្រួលខាងផ្នែកហិរញ្ញវត្ថុ ក្នុងពេលស្នាក់នៅផ្ទះ។ សូមមើលព័ត៌មានបន្ថែមស្តីពីកម្មវិធីរបស់រដ្ឋាភិបាល ដែលគាំទ្រការឈប់សម្រាកឈឺ និងសំណងរបស់កម្មករ

សម្រាប់ ជំងឺ COVID19, រួមមានសិទ្ធិឈប់សម្រាកឈឺរបស់និយោជិក ក្រោមច្បាប់ឆ្លើយតបជំងឺខ្សូរ៉ូណាវីរុសគ្រួសារជាចំបង និងសិទ្ធិរបស់និយោជិក ចំពោះអត្ថប្រយោជន៍សំណងរបស់កម្មករ និងការសន្មតថា ការងារដែលជាប់ទាក់ទងនឹងជំងឺ COVID-19 ដែលបានកើតឡើងនៅចន្លោះថ្ងៃទី១៩ ខែមិនា និងថ្ងៃទី ៥ ខែកក្កដា ដោយអនុលោមតាមបទបញ្ជាប្រតិបត្តិរបស់អភិបាលរដ្ឋ លេខ N-62-20។

- ដំណើរការការងារត្រូវបានកំណត់ឡើងវិញ តាមលទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីបង្កើនឱកាសសម្រាប់និយោជិកធ្វើការពីផ្ទះ។
- នៅពេលទទួលបានដំណឹងថានិយោជិក, ធ្វើតេស្តវិជ្ជមាន, ឬមានរោគសញ្ញាស្របគ្នាទៅនឹងជំងឺ COVID-19 (ករណី), ក្រុមត្រូវមានផែនការ ឬពិធីសារដើម្បីអោយករណី ដាក់ខ្លួនគេអោយនៅឯកោនៅផ្ទះ ហើយតម្រូវអោយដាក់អោយនៅឃ្លាតដាច់ឆ្ងាយពីគេ ឬការធ្វើចត្តាឡីស័កខ្លួនឯង ភ្លាមៗចំពោះ ឬនៃនិយោជិកទាំងអស់ ដែលមានការប្រឈមនៅនឹងកន្លែងធ្វើការ ទៅនឹងករណី។ ផែនការរបស់និយោជក គួរតែពិចារណាលើពិធីការសម្រាប់និយោជិកដែលបានដាក់ខ្លួនអោយនៅឃ្លាតដាច់ឆ្ងាយពីគេទាំងអស់ ដើម្បីអោយមានលទ្ធភាពធ្វើតេស្ត ឬត្រូវបានធ្វើតេស្ត សំរាប់ជំងឺ COVID-19 ដើម្បីកំណត់ថា តើមានការប្រឈមនៅកន្លែងធ្វើការបន្ថែមទៀតដែរឬទេ, ដែលអាចតម្រូវអោយមានវិធានការណ៍ត្រួតពិនិត្យជំងឺ COVID-19 បន្ថែម។ សូមមើលការ ណែនាំសុខភាពសាធារណៈ ស្តីពីការឆ្លើយតបទៅនឹងជំងឺ COVID-19 នៅកន្លែងធ្វើការ។
- ការចំរាញ់ ឬត្រួតពិនិត្យនិយោជិក ត្រូវបានធ្វើឡើងមុនពេលដែលបុគ្គលិកអាចចូលធ្វើការ។ ការត្រួតពិនិត្យត្រូវតែ រាប់បញ្ចូលការឆែកឆេរទាក់ទងនឹងការក្អក, ដង្ហើមខ្លី ឬដង្ហក់, ពិបាកដកដង្ហើម និងគ្រុនក្តៅ ឬញាក់ ហើយប្រសិនបើនិយោជិកមានទំនាក់ទំនងជាមួយមនុស្សដែលត្រូវបានគេស្គាល់ថា បានឆ្លងជំងឺ COVID-19 ក្នុងរយៈពេល ១៤ ថ្ងៃចុងក្រោយ។ ការត្រួតពិនិត្យទាំងនេះ អាចត្រូវបានធ្វើឡើងពីចម្ងាយ ឬដោយផ្ទាល់ នៅពេលមកដល់របស់និយោជិក។ ផងដែរ ការត្រួតពិនិត្យសីតុណ្ហភាព ក៏គួរតែត្រូវបានធ្វើ នៅកន្លែងធ្វើការប្រសិនបើអាចធ្វើទៅបាន។
- ក្នុងករណីដែលមានករណីចំនួន ៣ ឬ ច្រើនជាងនេះ ត្រូវបានរកឃើញ នៅក្នុងកន្លែងធ្វើការងារ ក្នុងរយៈពេល ១៤ ថ្ងៃ និយោជក គួរតែរាយការណ៍ការផ្ទុះឡើងនេះ ទៅកាន់នាយកដ្ឋានសុខាភិបាល តាមលេខ ៥៦២-៥៧០-INFO។
- និយោជិកនានា ដែលមានទំនាក់ទំនងជាមួយអ្នកដទៃ ត្រូវបានផ្តល់ជូន, ដោយឥតគិតថ្លៃ, នូវគម្របមុខសមរម្យដែលគ្របច្រមុះ និងមាត់។ ការគ្រប គឺត្រូវពាក់ដោយនិយោជិក គ្រប់ពេលវេលាទាំងអស់ ក្នុងកំឡុងពេលថ្ងៃធ្វើការ លើកលែងតែ ទីកន្លែងដែលបុគ្គលិកកំពុងធ្វើការនៅក្នុងរថយន្ត, ការិយាល័យ, ឬបន្ទប់តែម្នាក់ឯង។ និយោជិកនានា ដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ពួកគេ ថាពួកគេមិនគួរពាក់គម្របមុខ គួរតែពាក់ខែលការពារមុខ ជាមួយ ឬដោយប្រើក្រវ៉ាត់នៅលើគែមខាងក្រោម, អោយត្រូវនឹងសេចក្តីណែនាំរបស់រដ្ឋ, ដរាបណាលក្ខ័ណ្ឌរបស់ពួកគេអនុញ្ញាតិអោយ។ ក្រវ៉ាត់ ដែលត្រូវបានបង្កើតជាទម្រង់សមក្លឹបល្អម នៅក្រោមចង្កា ត្រូវបានគេពេញចិត្ត។ ម៉ាស់ដែលមានវ៉ាល់មួយផ្លូវ មិនគួរត្រូវបានប្រើឡើយ។
- អតិថិជន, អ្នកលក់, និងអ្នកម៉ៅការបន្ត, ឬអ្នកដែលមិនមែនជានិយោជិក ត្រូវពាក់គម្រប មុខគ្រប់ពេលវេលាទាំងអស់ នៅពេលកំពុងបំពេញការងារ។ មិនត្រូវពាក់គម្របដល់កុមារក្មេងៗ ដែលមានអាយុក្រោម ២ ឆ្នាំ, អ្នកណាម្នាក់ ដែលមានលក្ខ័ណ សុខភាព, លក្ខ័ណសុខភាពផ្លូវចិត្ត, ឬពិការភាពដែលរារាំងពួកគេមិនអាចអោយពាក់គម្របមុខបាន, ឬបើមិនដូច្នេះទេ ពួកគេមិនអាចដោះម៉ាស់ ឬគម្របមុខក្រណាត់ចេញបាន ដោយគ្មានជំនួយនោះឡើយ។

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

- ☐ និយោជិកទាំងអស់ត្រូវបានគេប្រាប់ មិនឱ្យមកធ្វើការ ប្រសិនបើឈឺ។
- ☐ ការត្រួតពិនិត្យរោគសញ្ញានានា ត្រូវបានធ្វើឡើង មុនពេលនិយោជិកចូលទៅកាន់ទីកន្លែងធ្វើការ។ រាល់តុការងា របស្ថានីយ៍ការងារនីមួយៗ ត្រូវបានញែកដាច់ពីគ្នា ដោយយ៉ាងហោចណាស់ចំងាយប្រាំមួយ (៦) ហ្វីត។
- ☐ ចំងាយរាងកាយ រវាងនិយោជិក និងអតិថិជនទាំងឡាយបានត្រូវបង្កើនឡើង (ឧទាហរណ៍ ការបើកបរឆ្លងកាត់, របាំងបែងចែក, កញ្ចក់បាំងនៅតាមចំណុចនៃ ទីតាំងលក់)។
- ☐ នៅកន្លែងដែលអាចធ្វើទៅបាន, និយោជិកដែលអាចបំពេញភារៈកិច្ចរបស់ពួកគេពីផ្ទះបាន ត្រូវបានគេណែនាំអោយធ្វើដូច្នោះ។
- ☐ ការប្រជុំដែលអាចបត់បែនបាន (ឧទាហរណ៍ ការធ្វើសន្និសិទទូរគមនាគមន៍ ឬការធ្វើសន្និសីទវីដេអូ)។
- ☐ ជម្រើសធ្វើដំណើរដែលអាចបត់បែនបាន (ឧទាហរណ៍ ពន្យារពេលការប្រជុំ ឬព្រឹត្តិការណ៍ដែលមិនចាំបាច់)។
- ☐ ម៉ោងធ្វើការដែលអាចបត់បែនបាន (ឧទាហរណ៍ ដាក់វេនធ្វើការបន្តបន្ទាប់គ្នា)។
- ☐ បញ្ជូន ឬផ្តល់សេវាកម្មពីចម្ងាយ (ឧទាហរណ៍ តាមទូរស័ព្ទ, តាមវីដេអូ ឬតាមវេប)។
- ☐ បន្ទប់សំរាក, បន្ទប់ទឹក និងកន្លែងទូទៅផ្សេងទៀត កំពុងត្រូវបានគេសំឡាប់មេរោគជាញឹកញាប់, ហើយបានស្តុកទុកនូវសំភារៈអនាម័យចាំបាច់នានា តាមកាលវិភាគដូចខាងក្រោមៈ

  - ☐ បន្ទប់សំរាក: បន្ទប់ទឹក:

  - ☐ ផ្សេងៗ:

  - ☐ ថ្នាំសំឡាប់មេរោគមានប្រសិទ្ធិភាពប្រឆាំងជំងឺ COVID-19 និងគ្រឿងផ្គត់ផ្គង់នានា សំរាប់និយោជិកទាំងអស់ អាចរកបានតាមទីតាំងនានា ដូចខាងក្រោម៖

- ☐ ទឹកធ្វើអនាម័យដៃសំឡាប់មេរោគមានប្រសិទ្ធិភាពប្រឆាំងជំងឺ COVID-19 សំរាប់និយោជិកទាំងអស់ អាចរកបាន តាមទីតាំងនានា ដូចខាងក្រោម៖

- ☐ សាប៊ូ និងទឹក សំរាប់និយោជិកទាំងអស់ អាចរកបានតាមទីតាំងនានា ដូចខាងក្រោមៈ

- ☐ និយោជិកត្រូវបានតំរូវអោយ និងអនុញ្ញាតិអោយមានពេលវេលាគ្រប់គ្រាន់ សម្រាប់លាងដៃរបស់ពួកគេ យ៉ាងហោចណាស់រៀងរាល់ ៣០ នាទីម្តង ឬនៅពេលដែលមានតំរូវការ ប្រសិនបើស្រោមដៃបានត្រូវផ្តល់អោយ។ នៅកន្លែងដែលការលាងដៃ គឺមិនអាចអនុវត្តបាន, ទឹកធ្វើអនាម័យដៃ ដែលមានជាតិអាល់កុលយ៉ាងហោចណាស់ ៦០% ត្រូវបានផ្តល់ទៅដល់និយោជិកជំនួសវិញ។

- ☐ ច្បាប់ចតចំលងនៃពិធីការនេះ ត្រូវបានចែកចាយដល់និយោជិកគ្រប់ៗគ្នា។

- ☐ ស្រេចលើចិត្ត — ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត:

  និយោជិកដែលមានទំនាក់ទំនងជាមួយអ្នកដទៃត្រូវបានផ្តល់ជូនដោយឥតគឹតថ្លៃ នូវគម្របមុខសមរម្យដែលគ្របច្រមុះ និងមាត់។ គម្របមុខ គឺត្រូវពាក់ដោយនិយោជិកគ្រប់ពេលវេលាទាំងអស់ នៅពេលថ្ងៃធ្វើការ លើកលែងតែនិយោជិកកំពុងធ្វើការនៅក្នុងយានយន្ត, ការិយាល័យ ឬបន្ទប់តែម្នាក់ឯង។ និយោជិកដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្រ្តរបស់ពួកគេ ដែលថាពួកគេមិនត្រូវពាក់គម្របមុខ គួរតែពាក់ខែលការពារមុខដោយប្រើក្រវ៉ាត់នៅលើគែមខាងក្រោម, អោយត្រូវ ឬអនុលោមទៅតាមសេចក្តីណែនាំរបស់រដ្ឋ, ប្រសិនបើលក្ខ័ណ្ឌរបស់ពួកគេអាចអោយធ្វើដូច្នេះបាន។ តម្រូវអោយមានទំពក់ ឬប្រដាប់ជួយបិទអោយសមល្មមសមនៅក្រោមចង្កា។ មិនត្រូវប្រើម៉ាស់ ដែលមានវ៉ាល់/សន្ទះមួយផ្លូវ នោះឡើយ។

- ☐ និយោជកត្រូវធានាថាកម្មកររក្សាចម្ងាយ ៦ ហ្វីត ពីអ្នកដទៃពេលណាអាចធ្វើទៅបាន។ នៅពេលដែលមិនអាចធ្វើទៅបាន, ការធ្វើអន្តរកម្មឬការទំនាក់ទំនងគ្នាទៅមក នៃចំងាយ និងភាពញឹកញាប់ គួរតែត្រូវ រក្សាអោយបានជាអប្បបរមាបំផុត។ នៅពេលដែលកាតព្វកិច្ចការងារ តម្រូវឱ្យមានអន្តរកម្មជាទៀងទាត់នោះ, និយោជិកគួរតែផ្តល់របាំងបន្ទាប់បន្សំអោយទៅកម្មករប្រើប្រាស់ (ឧទាហរណ៍ របាំងមុខ ឬវ៉ែនតាសុវត្ថិភាព) ដែលមានបំណងចង់ប្រើមួយនូវរបស់ទាំងនោះ និងអនុញ្ញាតឱ្យកម្មករប្រើរបស់របរទាំងនោះផ្ទាល់ខ្លួនរបស់ពួកគេ ប្រសិនបើពួកគេចង់ប្រើ។

- ☐ បង្កើតឡើងនូវពេលវេលាចាប់ផ្តើមធ្វើការ និងការផ្លាស់ប្តូរវេនបន្តបន្ទាប់គ្នា សម្រាប់បុគ្គលិក ដើម្បីកំណត់ចំនួនបុគ្គលិកនៅនឹងកន្លែង, ការប្រជុំក្រុម, នៅឯពេលសំរាកអាហារថ្ងៃត្រង់ និងកំឡុងពេលចេញដំណើរពីធ្វើការ។ គ្មាននរណាម្នាក់ ត្រូវបានអនុញ្ញាតិអោយប្រមូលផ្តុំជាក្រុមឡើយ។

- ☐ ការប្រជុំបុគ្គលិក ត្រូវបានធ្វើឡើងនៅទីវាលបើកចំហរ ដូចជា នៅចំណតរថយន្ត ឬកន្លែងស្តុកឥវ៉ាន់ធំៗ ដើម្បីរក្សានូវគំលាតឆ្ងាយរាងកាយពីគ្នា។

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

- មិនអនុញ្ញាតអោយភ្ញៀវ ឬអ្នកតំណាងលក់ នៅលើ ឬនៅក្នុងកន្លែង មជ្ឈមណ្ឌលវាយតិន្ទីសឡើយ។ នេះរួមបញ្ចូលទាំង អ្នកចែកចាយខាងក្រៅ និងអ្នកតំណាងក្រុមហ៊ុនផលិតទាំងឡាយ។ ការប្រជុំ ត្រូវបានធ្វើឡើងតាមទូរស័ព្ទ, ហ្សូម (zoom) ឬវេទិកានិម្មិត/តាមអ៊ីនធឺណេិតផ្សេងៗ។
- ការប្រើប្រាស់នាឡិកាពេលវេលាគួរត្រូវបានបញ្ឈប់ ប្រសិនបើអាចធ្វើទៅបាន។
- តំរូវ និងអនុញ្ញាតិអោយបុគ្គលិកមានពេលវេលាគ្រប់គ្រាន់ ដើម្បីលាងសំអាត ឬធ្វើអនាម័យដៃរបស់ពួកគេ រៀងរាល់ ៣០ នាទីម្តង ឬទៅតាមតម្រូវការ ប្រសិនបើមានការផ្តល់អោយនូវស្រោមដៃ។ កន្លែងបន្ទប់ទូរចាក់សោរ ដាក់ឥវ៉ាន់ ត្រូវបានសម្អាតអោយអស់នូវរបស់របរផ្ទាល់ខ្លួន។ ឯកសណ្ឋានបន្ថែម, ប្រដាប់ប្រដារ និងរបស់របរផ្ទាល់ខ្លួនទាំងអស់ អាចត្រូវបានរក្សាទុកនៅក្នុងយានយន្តផ្ទាល់ខ្លួន នៅនឹងកន្លែង។ មិនមានការអនុញ្ញាតិ អោយរក្សាទុក នូវរបស់របរផ្ទាល់ខ្លួន នៅនឹងកន្លែងឡើយ។
- ការប្រើប្រាស់ របស់របរប្រើប្រាស់ទូទៅនៅបន្ទប់សំរាក (ឧទាហរណ៍ ប៉ាន់កាហ្វេ, ម៉ាស៊ីនលក់, ទូរទឹកកក និងមៃក្រូវ៉េវ) ត្រូវបានផ្អាក។ ម៉ាស៊ីនធ្វើអោយត្រជាក់ផ្ទាល់ខ្លួន ត្រូវបានណែនាំសម្រាប់ពេលញ៉ាំអាហារ/ភេសជ្ជៈផ្ទាល់ខ្លួន ហើយគួរតែទុកនៅក្នុងយានយន្តផ្ទាល់ខ្លួន។
- កន្លែងសសំរាក និងអាហារថ្ងៃត្រង់ទីពីរ ត្រូវបានបង្កើតឡើង ប្រសិនបើអាចធ្វើទៅបាន ដើម្បីអនុញ្ញាតិអោយមានការឃ្លាតឆ្ងាយរាងកាយពីគ្នា បានកាន់តែទូលាយជាងមុន។
- គណៈគ្រប់គ្រងនឹងកំណត់នូវគោលការណ៍ណែនាំនានា សម្រាប់ការសម្អាតកន្លែង យ៉ាងហោចណាស់បីដងក្នុងមួយថ្ងៃ; (ពេលព្រឹក បន្ទាប់ពីការមកដល់របស់បុគ្គលិក, និងក្រុមចាកចេញទៅកន្លែង បន្ទាប់ពីម៉ោងអាហារថ្ងៃត្រង់, និងនៅចុងបញ្ចប់នៃវេនការងារ នៅពេលដែលបុគ្គលិកគ្រប់រូប បានចាកចេញពីការងារនៃថ្ងៃនោះ ហើយផ្តោតលើចំណុចដែលបានប៉ះពាល់ទាំងអស់ (កន្លែងមួលកាន់តាមមាត់ទ្វារ, បន្ទប់ទឹក, តុ, កៅអី, ស្នូកផ្តុកទឹក, កុំព្យូទ័រ/ក្តារចុច ។ល។) កន្លែងដែលប៉ះពាល់ច្រើន អាចត្រូវការនូវការសំអាតអោយបានញឹកញាប់។

## G. នីតិវិធីចុងបញ្ចប់នៃវេន

- បុគ្គលិកមានការទទួលខុសត្រូវក្នុងការសំឡាប់មេរោគ ចំពោះឧបករណ៍ប្រើប្រាស់ បន្ទាប់ពីប្រតិបត្តិការរួច។ មានវត្ថុសំឡាប់មេរោគ នៅតាមស្ថានីយ៍ឧបករណ៍សំខាន់ៗ សម្រាប់អោយបុគ្គលិកជូតជំរះ ឬសំអាតនូវឧបករណ៍នានា មុន និងក្រោយពេលប្រើ។
- តំរូវអោយបុគ្គលិកទាំងអស់ ត្រូវចាកចេញពីទ្រព្យសម្បត្តិភ្លាមៗ បន្ទាប់ពីចប់វេនការងារ របស់ពួកគេ។
- សមាជិកក្រុមនីមួយៗត្រូវបានរំលឹក អំពីសារៈសំខាន់នៃការឃ្លាតឆ្ងាយរាងកាយពីគ្នា ពេលចេញពីការងារ ក៏ដូចជា ក្នុងកំឡុងពេលបំពេញការងារ។

| H. ពិធីការត្រួតពិនិត្យ |
|---|

- ប្រតិបត្តិករមជ្ឈមណ្ឌលតិន្នីសមាន 'ឯកអគ្គរដ្ឋទូតសុវត្ថិភាព' ម្នាក់ នៅនឹងកន្លែងក្នុងអំឡុងរាល់ពេលម៉ោងធ្វើការទាំងអស់។ គោលបំណងតែមួយគត់ នៃបុគ្គលិកដែលត្រូវបានគេនិយាយនោះ គឺដើម្បីធានាថា បុគ្គលិក និងភ្ញៀវទាំងឡាយ អនុវត្តតាមនូវរាល់តម្រូវការនានា នៃពិធីការសុវត្ថិភាពនៅឃ្លាតឆ្ងាយពីគ្នា។ ឯកអគ្គរដ្ឋទូតសុវត្ថិភាពពាក់ស្លាកឈ្មោះ ហើយមានសញ្ញាសំគាល់ ថាពួគគេ គឺជា "ឯកអគ្គរដ្ឋទូតសុវត្ថិភាព"។ ឯកអគ្គរដ្ឋទូតសុវត្ថិភាពតែងតែមាននូវឯកសារនេះ ជាប់ជាមួយនឹងពួកគេ ដើម្បីយោងអំពីពិធីការសុវត្ថិភាពនានា ដែលមានតំរូវការ។
- ការរួសរាយរាក់ទាក់, ប៉ុន្តែការប្រាស្រ័យទាក់ទងយ៉ាងម៉ឺងម៉ាត់ ជាមួយនឹងភ្ញៀវណាដែលរំលោភបំពានលើតំរូវការនៃ ពិធីការសុវត្ថិភាព គឺជាកត្តាចាំបាច់។ ភ្ញៀវទាំងឡាយ ត្រូវបានក្រើនរំលឹកថា រាល់ការបំពារបំពានណាមួយ នៃពិធីការសុវត្ថិភាពនៅឃ្លាតឆ្ងាយពីគ្នា នឹងបង្កនូវភាពអន្តរាយដល់ការបន្តនូវប្រតិបត្តិការ នៃមជ្ឈមណ្ឌលតិន្នីសនានា ក្នុងស្រុក។
- ភ្ញៀវណាម្នាក់, ដែលបដិសេធមិនគោរពតាមពិធីការសុវត្ថិភាពនានា បន្ទាប់ពីផ្តល់នូវការព្រមានម្តងរួចហើយនោះ ត្រូវបានស្នើសុំអោយចាកចេញ ពីទ្រព្យសម្បត្តិភ្លាម។

## វិធានការណ៍បន្ថែមណាមួយ ដែលមិនបានដាក់បញ្ចូលខាងលើ គួរតែត្រូវបាន ដាក់រាយ នៅលើទំព័រដាច់ដោយឡែក, ដែលអាជីវកម្ម គួរតែភ្ជាប់ជាមួយនឹងឯកសារនេះ

**អ្នកអាចទាក់ទងមនុស្សខាងក្រោមនេះ បើសិនជាអ្នកមានសំណួរ ឬយោបល់នានា អំពីពិធីការនេះ:**

ឈ្មោះទំនាក់ទំនង មជ្ឈមណ្ឌលតិន្នីស: ______________________ លេខទូរស័ព្ទ: ______________________

កាលបរិច្ឆេទកែប្រែ ចុងក្រោយ: ______________________

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**